មើលវីដេអូ ភាគទី ២៩

# អកុសលកម្មបថ ១០

## ១ - កាយកម្ម ៣ គឺ ៖

- *បាណាតិបាត* ការសម្លាប់សត្វ
- *អទិន្នាទាន* ការលួចទ្រព្យអ្នកដទៃ
- *កាមេសុមិច្ឆាចារ* ការប្រព្រឹត្តខុសក្នុងកាម

## ២ - វចីកម្ម ៤ គឺ ៖

- *មុសាវាទ* កានិយាយពាក្យកុហក
- *បិសុណាវាទ* ការនិយាយពាក្យញុះញង់
- *ផរុសវាទ* ការនិយាយពាក្យគ្រោតគ្រាត
- *សម្ផប្បលាប* ការនិយាយឥតប្រយោជន៍

## ៣ - មនោកម្ម ៣ គឺ ៖

- *អភិជ្ឈា* ការសំឡឹងរំពៃចង់បានទ្រព្យគេ
- *ព្យាបាទ* ការចងអាឃាតព្យាបាទ
- *មិច្ឆាទិដ្ឋិ* ការយល់ខុស

ស្កេនដើម្បីមើលមេរៀន

San Sochea Official


អកុសលមូល ៣
(ឬអកុសលហេតុ)
លោភមូល
ទោសមូល
មោហមូល

# វិនិច្ឆ័យអកុសលកម្មបថ ១០ ដោយអាការ ៥

១- ដោយមូល

២- ដោយកម្ម

៣- ដោយទ្វារ

៤- ដោយទោស

៥- ដោយអង្គ

# វិនិច្ឆ័យបាណាតិបាត
# ដោយអាការ៩

*១- ដោយមូល* ការសម្លាប់សត្វ គិតដោយមូល មានមូល២ គឺ ៖ មោហមូល និងទោសមូល ដែលកើតក្នុងទោសមូលចិត្ត ២ ដួង

*ទោសមូលចិត្ត*



# ចិត្តជាហេតុឲ្យដាច់បាណាតិបាត គឺទោសមូលចិត្ត២ដួង



បាណាតិបាត

ពោលដោយកម្ម

គឺជាកាយកម្ម



ទ្វារនៃកម្មបថមាន៣ គឺ កាយទ្វារ វចីទ្វារ និងមនោទ្វារ



សម្លាប់ដោយខ្លួនឯង

បាណាតិបាត ពោលដោយទ្វារ កើតតាមទ្វារ ២ គឺ

- កាយទ្វារ
- និងវចីទ្វារ



ប្រើគេឲ្យសម្លាប់

បាណាតិបាត
ចាត់ជាកាយកម្ម
និងមានទ្វារ ២

កាយកម្ម កាយទ្វារ



សម្លាប់
ដោយខ្លួនឯង

កាយកម្ម វចីទ្វារ



ប្រើគេ
ឲ្យសម្លាប់

២ - ដោយកម្ម ជាកាយកម្ម

៣ - ដោយទ្វារ សម្រេចតាមទ្វារ២ គឺ កាយទ្វារ និងវចីទ្វារ

៤ - ដោយទោស មានទោសខុសគ្នាយ៉ាងនេះ

- សម្លាប់សត្វដែលមានសេចក្តីល្អច្រើន មានទោសច្រើន
- សម្លាប់សត្វដែលមានសេចក្តីល្អតិច មានទោសតិច
- កិលេសនិងការព្យាយាមខ្លាំង មានទោសច្រើន
- កិលេសនិងការព្យាយាមខ្សោយ មានទោសតិច

## ៥- ដោយអង្គ បាណាតិបាត មានអង្គ៥ គឺ ៖

- បាណោ សត្វមានជីវិត
- បាណសញ្ញិតា សេចក្តីដឹងថា សត្វមានជីវិត
- វធកចិត្តំ គិតនឹងសម្លាប់
- ឧបក្កមោ ព្យាយាមនឹងសម្លាប់
- តេន មរណំ សត្វស្លាប់ដោយការព្យាយាមនោះ។

** កាលណាគ្រប់អង្គទាំង៥ ឈ្មោះថាដាច់កម្មបថ (សីលក៏ឈ្មោះថាដាច់ដែរ) បើមិនគ្រប់អង្គ មិនឈ្មោះថាដាច់កម្មបថទេ ប៉ុន្តែអាចជាទុច្ចរិតកម្ម។*